ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការយុទ្ធសាស្ត្រ
# នាយកដ្ឋានគោលនយោបាយ ឆ្នាំ ២០២១-២០២៥

នាយកដ្ឋានគោលនយោបាយ

ខែតុលា ឆ្នាំ ២០២០

# ផែនការយុទ្ធសាស្ត្រ
# នាយកដ្ឋានគោលនយោបាយ
# ២០២១-២០២៥

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាគឺជាស្ថាប័នមួយដែលមានចក្ខុវិស័យកសាងធនធានមនុស្សឱ្យមានគុណភាពខ្ពស់ និងក្រមសីលធម៌ ដើម្បីរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឆ្ពោះទៅបង្កើតសង្គមពុទ្ធិ។ ចក្ខុវិស័យនេះ ស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ ដែលកម្ពុជាមានមហិច្ឆតាប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០។

គន្លងនៃកំណើនសេដ្ឋកិច្ចដែលបានរំពឹងទុកនេះ ជាបន្ទុកធ្ងន់ធ្ងរសម្រាប់វិស័យអប់រំក្នុងការបំពេញចក្ខុវិស័យរបស់ខ្លួន។ គ្រប់ទិដ្ឋភាពនៃវិស័យអប់រំ ត្រូវការកំណែទម្រង់ដែលមានលក្ខណៈស៊ីជម្រៅ និងអាចអនុវត្តបាន ដើម្បីឱ្យប្រទេសកម្ពុជាសម្រេចបាននូវចក្ខុវិស័យដ៏ជ្រាលជ្រៅរបស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើត និងអនុវត្តគោលនយោបាយ ព្រមទាំងយុទ្ធសាស្ត្រជាច្រើនដើម្បីដោះស្រាយបញ្ហាខ្វះធនធានមនុស្ស ជំនាញ និងពុទ្ធិ ដោយកំណត់ឡើងវិញនូវជំនាញ និងពុទ្ធិដែលមានភាពឆ្លើយតបទៅនឹងបរិបទកម្ពុជា និងអន្តរជាតិ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ គឺជាឯកសារសំខាន់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធានាលទ្ធភាពទទួលបានការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ព្រមទាំងធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំបច្ចុប្បន្នគឺជាឯកសារចង្អុលបង្ហាញផ្លូវដើម្បីដោះស្រាយបញ្ហានៃការទទួលបានការអប់រំចំណេះដឹងទូទៅ និងគុណភាពនៃប្រព័ន្ធអប់រំគ្រប់កម្រិតថ្នាក់ ដើម្បីធានាថាអត្រាបញ្ចប់ការសិក្សានឹងកើនឡើងជាសារវន្ត។

ក្រសួងអប់រំ យុវជន និងកីឡាបានគាំទ្រការស្រាវជ្រាវ និងលើកទឹកចិត្តការប្រើលទ្ធផលនៃការស្រាវជ្រាវជាភស្តុតាងជាក់ស្តែងក្នុងការបង្កើត និងការអនុវត្តគោលនយោបាយប្រកបដោយនវានុវត្តន៍។

ផែនការយុទ្ធសាស្ត្រទាំង ១៤ ចំណុចរបស់នាយកដ្ឋានគោលនយោបាយមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចធ្វើបានសម្រេច ប្រាកដនិយម និងអនុវត្តបានទាន់ពេលវេលា។

ក្រសួងអប់រំ យុវជន និងកីឡារំពឹងថាវប្បធម៌នៃការស្រាវជ្រាវ និងការប្រើប្រាស់លទ្ធផលស្រាវជ្រាវ ការចែករំលែកចំណេះដឹងសម្រាប់បង្កើតគោលនយោបាយ ការកែលម្អការអនុវត្តគោលនយោបាយ និងការប្រតិបត្តិវិជ្ជាជីវៈនានា ត្រូវបានដាំបណ្តុះនៅក្នុងវិស័យអប់រំគ្រប់កម្រិត ដើម្បីជំរុញការប្រែក្លាយកម្ពុជាពី

ប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើកម្លាំងពលកម្មទៅជាប្រទេសដែលពឹងផ្អែកលើពុទ្ធិដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។

ក្រសួងអប់រំ យុវជន និងកីឡា សូមសំដែងនូវការកោតសរសើរដ៏ស្មោះចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីទាំងអស់ ដែលបានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រ នាយកដ្ឋានគោលនយោបាយ ២០២១-២០២៥ ឱ្យសម្រេចបានជាស្ថាពរ។ ក្រសួងសង្ឃឹមថា នាយកដ្ឋានគោលនយោបាយនឹងអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យទទួលបានផ្លែផ្កា ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## មាតិកា


**អារម្ភកថា** ........ i

**១. ប្រវត្តិនាយកដ្ឋានគោលនយោបាយ** ........ ១

**២. វិភាគស្ថានភាពរបស់នាយកដ្ឋានគោលនយោបាយដោយប្រើ SWOT** ........ ១

ភាពខ្លាំង ........ ២

ភាពខ្សោយ ........ ២

ឱកាស ........ ៣

ការគំរាមកំហែង ........ ៤

**៣. ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ** ........ ៤

ចក្ខុវិស័យ ........ ៤

បេសកកម្ម ........ ៤

គុណតម្លៃ ........ ៥

**៤. យុទ្ធសាស្ត្រ** ........ ៥

លទ្ធផលទី ១៖ បង្កើតគោលនយោបាយអប់រំផ្អែកលើការស្រាវជ្រាវប្រកបដោយនវានុវត្តន៍ និងស្រប តាមបរិបទកម្ពុជា និងអតិក្រមនៃការចូលរួម ........ ៥

លទ្ធផលទី ២៖ ច្នៃប្រឌិតការបង្រៀន ការរៀន វាយតម្លៃ និងអភិបាលកិច្ចសាលារៀនដោយផ្អែក លើទ្រឹស្តី និងឧត្តមានុវត្តន៍ ........ ៩

លទ្ធផលទី ៣៖ លើកកម្ពស់ការចែករំលែកចំណេះដឹង និងការបង្កើតសហគមន៍រៀនសូត្រ........ ១២

លទ្ធផលទី ៤៖កាត់បន្ថយបញ្ហាគម្លាតនៃគោលនយោបាយអប់រំនិងការអនុវត្តគោលនយោបាយ.១៤

លទ្ធផលទី ៥៖ ពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលឱ្យស្របតាមបរិបទសតវត្សរ៍ទី ២១ សម័យ ឌីជីថល និងដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព........ ១៦

**៥. ធនធានហិរញ្ញវត្ថុ** ........ ២២

**៦. តាមដាន និងវាយតម្លៃ** ........ ២២

## ១. ប្រវត្តិនាយកដ្ឋានគោលនយោបាយ

នាយកដ្ឋានគោលនយោបាយ គឺជាអង្គភាពមួយស្ថិតក្រោមអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការដែលបានបង្កើតឡើងក្នុងឆ្នាំ២០១៥ យោងតាមអនុក្រឹត្យលេខ ៥៨.អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីសិក្សាស្រាវជ្រាវគោលនយោបាយអប់រំ អភិវឌ្ឍគោលនយោបាយអប់រំ និងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ យុវជន និងកីឡា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្តល់នូវគំនិត និងលើកជាយោបល់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការសម្រេចចិត្តពាក់ព័ន្ធទៅនឹងការធ្វើកំណែទម្រង់វិស័យអប់រំ។ ចាប់តាំងពីឆ្នាំ២០១៩ នាយកដ្ឋានគោលនយោបាយ ក៏បានដើរតួនាទីជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាស្រាវជ្រាវអប់រំផងដែរ តាមប្រកាសលេខ ២៨២ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលជាធនាគារខួរក្បាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ២. វិភាគស្ថានភាពរបស់នាយកដ្ឋានគោលនយោបាយដោយប្រើ SWOT

ការវិភាគស្ថានភាពនាយកដ្ឋានគោលនយោបាយ ត្រូវបានធ្វើឡើងតាមរយៈការវិភាគ SWOT ដើម្បីកំណត់ភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន ព្រមទាំងឱកាសនិងការគំរាមកំហែងនានា ដែលអាចមានឥទ្ធិពលមកលើនាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ យុវជន និងកីឡា។ ការវិភាគកត្តាខាងក្នុង(ភាពខ្លាំងនិងភាពខ្សោយ) អាចជួយឱ្យនាយកដ្ឋានមានការយល់ដឹងពីស្ថានភាពធនធានមនុស្ស ភាពជាអ្នកដឹកនាំ វប្បធម៌ និងកិត្យានុភាពរបស់អង្គភាពជាដើម។ ជាមួយគ្នានេះដែរ អភិបាលកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងសម្ភារូបវន្ត និងការគ្រប់គ្រងផ្នែកបច្ចេកវិទ្យារបស់អង្គភាពត្រូវបានវិភាគនិងកត់ត្រា។ ការវិភាគនេះជួយអង្គភាពឱ្យបានដឹងពីស្ថានភាពហិរញ្ញវត្ថុ និងសមត្ថភាពក្នុងការកៀរគរធនធានហិរញ្ញវត្ថុ សម្រាប់អនុវត្តសកម្មភាពជាអាទិភាពនានា។

ការយល់ដឹងពីកត្តាខាងក្រៅ អាចជួយឱ្យនាយកដ្ឋានគោលនយោបាយកំណត់ស្ថានភាពអំណោយផលសម្រាប់ពង្រឹង និងពង្រីកកិច្ចសហការ ព្រមទាំងអាចកាត់បន្ថយនូវហានិភ័យ និងការគំរាមកំហែងនានាពីប្រភពខាងក្រៅមកលើអង្គភាព។

- **ភាពខ្លាំង**

មន្ត្រីនាយកដ្ឋានគោលនយោបាយ គឺជាក្រុមមនុស្ស ដែលមានសក្តានុពលក្នុងការបំពេញការងារ មានគុណវុឌ្ឍិខ្ពស់ និងបានទទួលការបណ្តុះបណ្តាលលើជំនាញផ្សេងៗទាំងក្នុងនិងក្រៅប្រទេស។ ថ្នាក់ដឹកនាំមានអធ្យាស្រ័យល្អ លើកទឹកចិត្ត និងទទួលស្គាល់ការខិតខំប្រឹងប្រែងរបស់មន្ត្រីក្នុងការអភិវឌ្ឍសមត្ថភាពជាប្រចាំ។ កេរ្តិ៍ឈ្មោះនាយកដ្ឋានគោលនយោបាយត្រូវបានផ្សព្វផ្សាយ និងមានការទទួលស្គាល់ថាជាអង្គភាពដែលទទួលបន្ទុកការស្រាវជ្រាវ និងរៀបចំគោលនយោបាយអប់រំ។

ក្រៅពីចំណុចដូចរៀបរាប់ខាងលើ មន្ត្រីនាយកដ្ឋានគោលនយោបាយមានឆន្ទៈខ្ពស់ក្នុងការបំពេញការងារ មានស្មារតីទទួលខុសត្រូវខ្ពស់លើការងារ និងមានក្រមសីលធ៌មវិជ្ជាជីវៈ។ នាយកដ្ឋានគោលនយោបាយបានបំពាក់ទៅដោយសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ និងមានបរិស្ថានការងារសមស្របសម្រាប់គាំទ្រការបំពេញការងារប្រចាំថ្ងៃ។ ក្នុងនោះដែរ យើងក៏មានបន្ទប់ធនធានប្រមូលផ្តុំនូវសៀវភៅ និងឯកសារផ្សេងៗ ជាច្រើនសម្រាប់ឱ្យបុគ្គលិកនាយកដ្ឋានស្រាវជ្រាវ រៀនសូត្រ និងបង្កើនចំណេះដឹងរបស់ខ្លួន។ ជាមួយគ្នានេះដែរ នាយកដ្ឋានគោលនយោបាយ មានលទ្ធភាពអាចកៀរគរធនធានហិរញ្ញវត្ថុបានគ្រប់គ្រាន់សម្រាប់គាំទ្រការបំពេញការងារ។ អភិបាលកិច្ចល្អគឺជាចំណុចខ្លាំងមួយបន្ថែមទៀត ដែលជំរុញឱ្យការអនុវត្តការងារមានភាពច្បាស់លាស់ និងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់។ សាមគ្គីភាព និងស្មារតីក្រុមជាវប្បធម៌និងគុណតម្លៃដែលបានអនុវត្តជាយូរមកហើយនៅក្នុងនាយកដ្ឋានគោលនយោបាយ។ ម៉្យាងទៀត នាយកដ្ឋានគោលនយោបាយកំពុងរៀបចំប្រព័ន្ធគ្រប់គ្រងបែបឌីជីថលតាមរយៈការបង្កើតវេបសាយ ការគ្រប់គ្រងរដ្ឋបាល អេឡិចត្រូនិច និងការរៀបចំបន្ទប់ធនធានទូរនិម្មិតដែលជួយឱ្យការគ្រប់គ្រងអង្គភាពកាន់តែមានប្រសិទ្ធភាព និងជាវេទិកាផ្តល់ចំណេះដឹងដល់អ្នករៀបចំគោនយោបាយអប់រំ មន្ត្រីអប់រំ សិស្ស និស្សិត និងសាធារណជនផងដែរ។

- **ភាពខ្សោយ**

នាយកដ្ឋានគោលនយោបាយជាអង្គភាពថ្មី ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៥។ ចំនួនមន្ត្រីមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនិងទំហំការងារនៅឡើយដែលជាហេតុធ្វើឱ្យមន្ត្រីម្នាក់ៗ ជាពិសេសមន្ត្រីដែលមានសមត្ថភាពខ្ពស់ត្រូវទទួលបន្ទុកកិច្ចការច្រើន។ ជាមួយគ្នានេះដែរ នាយកដ្ឋានគោលនយោបាយខ្វះមន្ត្រីទទួលបន្ទុកផ្នែកពិនិត្យគុណភាព ដើម្បីពិនិត្យរបាយការណ៍ស្រាវជ្រាវ ការប្រើប្រាស់ភាសាខ្មែរក្នុងអត្ថបទស្រាវជ្រាវ និងឯកសារគោលនយោបាយមួយចំនួនទៀត ក៏ដូចជាមន្ត្រីដែលមានជំនាញខាងរចនាគេហទំព័រជាដើម។ លើសពីនេះទៅទៀត កិច្ចការមួយចំនួនត្រូវឱ្យបំពេញឱ្យបានរួចរាល់ក្នុងរយៈពេល

កំណត់ខ្លី និងមិនបានកំណត់ក្នុងផែនការដែលបានគ្រោងទុក ជាហេតុនាំឱ្យមន្ត្រីត្រូវតែខិតខំបំពេញឱ្យខានតែបានដែលអាចនាំឱ្យមានបញ្ហាសុខភាព។

ការរៀបចំផែនការសកម្មភាព សម្រាប់ការិយាល័យមិនទាន់ឆ្លើយតបតាមផែនការយុទ្ធសាស្ត្រអប់រំ កំណែទម្រង់អប់រំ និងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍនិងបច្ចេកវិទ្យាព័ត៌មានដែលជាហេតុនាំឱ្យនាយកដ្ឋានមិនអាចអនុវត្តតួនាទីជាធនាគារខួរក្បាលវិស័យអប់រំបានល្អនៅឡើយ។

មន្ត្រីមិនទាន់មានសមត្ថភាពក្នុងការរៀបចំផែនការច្បាស់លាស់សម្រាប់អនុវត្ត និងមិនទាន់យល់ដឹងអំពីគោលដៅ កម្មវត្ថុ អតិផល និងសូចនាករនៃគម្រោង ឬកម្មវិធីរបស់នាយកដ្ឋាន និងគោលនយោបាយជាយុទ្ធសាស្ត្រ។ មន្ត្រីមិនសូវមានការឆ្លុះបញ្ចាំង និងពិនិត្យឡើងវិញលើការអនុវត្តផែនការសកម្មភាព និងផែនការថវិកាជាប្រចាំ។ មន្ត្រីមិនមានការយល់ដឹងពីប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារ។

ការស្រាវជ្រាវ និងការសរសេររបាយការណ៍ស្រាវជ្រាវត្រូវការមន្ត្រីដែលមានជំនាញច្បាស់លាស់លើការស្រាវជ្រាវ មានសមត្ថភាពខ្ពស់លើការវិភាគនិងមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយដែលជាសមត្ថភាពត្រូវអភិវឌ្ឍបន្ថែម។ ក្រៅពីចំណុចដូចបានរៀបរាប់ខាងលើ ឯកសារណែនាំស្តីពីនីតិវិធីនៃការអភិវឌ្ឍគោលនយោបាយមិនទាន់ត្រូវបានរៀបចំនៅឡើយ។ ប្រព័ន្ធវាយតម្លៃគុណផលការងារថ្នាក់ដឹកនាំ និងមន្ត្រីមិនទាន់មាន។ ផ្នែករដ្ឋបាល ជាពិសេសរបៀបនៃការសរសេរលិខិតរដ្ឋបាល ការសរសេររបាយការណ៍(មិនទាន់ពេលវេលា និងមិនមានព័ត៌មានគ្រប់គ្រាន់ ដើម្បីឆ្លុះបញ្ចាំងពីការងារដែលនាយកដ្ឋានបានអនុវត្ត) និងការកត់ត្រាព័ត៌មានត្រូវការអភិវឌ្ឍបន្ថែមទៀត។ ការប្រាស្រ័យទាក់ទងទាំងក្នុងនិងក្រៅអង្គភាពចាំបាច់ត្រូវពង្រឹងបន្ថែម។ មន្ត្រីមិនទាន់មានការយល់ដឹងពីការចំណាយថវិកាទៅតាមគម្រោង និងនីតិវិធីហិរញ្ញវត្ថុ។

- **ឱកាស**

នាយកដ្ឋានគោលនយោបាយមានកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ស្ថាប័នអប់រំ និងស្ថាប័នស្រាវជ្រាវទាំងកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ទំនាក់ទំនងនេះ នឹងជួយឱ្យនាយកដ្ឋានគោលនយោបាយកាន់តែមានកេរ្តិ៍ឈ្មោះ និងការគាំទ្រនានាទាំងបច្ចេកទេសពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ។

ក្នុងកម្រិតស្ថាប័ន ការស្រាវជ្រាវបែបវិទ្យាសាស្ត្រត្រូវបានទទួលស្គាល់ថាមានភាពចាំបាច់ក្នុងការបង្កើតគោលនយោបាយអប់រំសំខាន់ៗនានា។ ក្នុងរយៈពេលចុងក្រោយនេះ នៅពេលដែលមានវិបត្តិសាកលនៃជំងឺកូវីដ-១៩ នាយកដ្ឋានគោលនយោបាយបានផ្តល់នូវការស្រាវជ្រាវប្រកបដោយលក្ខណៈ

វិទ្យាសាស្ត្រ ដែលនាំឱ្យឈានទៅដល់ការពិចារណាបើកដំណើរការឡើងវិញនូវសាលារៀនគ្រប់កម្រិត និងគ្រប់ភូមិសិក្សានៅទូទាំងប្រទេសតាមដំណាក់។

ការវិវឌ្ឍនៃបច្ចេកវិទ្យាឥតឈប់ឈរជាឱកាសសម្រាប់នាយកដ្ឋានគោលនយោបាយអាចអភិវឌ្ឍ និងផ្តួចផ្តើមគំនិតថ្មី ព្រមទាំងច្នៃប្រឌិតទាំងកម្រិតស្ថាប័ននិងបុគ្គល។

- **ការគំរាមកំហែង**

លទ្ធផលនៃការស្រាវជ្រាវ នៅមិនទាន់បានប្រើប្រាស់ឱ្យបានទូលំទូលាយដោយអង្គភាពពាក់ព័ន្ធមួយចំនួនទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំ។ ជាមួយគ្នានេះដែរ នីតិវិធីហិរញ្ញវត្ថុមានភាពស្មុគស្មាញ ដែលជាហេតុនាំឱ្យមានភាពយឺតយ៉ាវដល់ការទម្លាក់ថវិកាសម្រាប់គាំទ្រការស្រាវជ្រាវ។ លើសពីនេះទៅទៀត នាយកដ្ឋានគោលនយោបាយត្រូវការការគាំទ្របន្ថែមពីថ្នាក់ដឹកនាំលើការតម្រង់ទិសការសិក្សាស្រាវជ្រាវ និងជំរុញការប្រើប្រាស់លទ្ធផលស្រាវជ្រាវ។

នាយកដ្ឋានត្រូវមានភាពរឹងមាំ និងភាពធន់ឆ្លើយតបទៅនឹងវិបត្តិនានាដូចជា គ្រោះមហន្តរាយ ស្ថានភាពអាសន្ន ឬវិបត្តិនានា ដើម្បីអាចមានអត្ថិភាពនិងបន្តនិរន្តភាពក្នុងការផ្តល់សេវារបស់ខ្លួនបាន។ ការណ៍នេះ តម្រូវឱ្យនាយកដ្ឋានត្រូវមានប្រព័ន្ធឆ្លើយតប ដែលមានប្រសិទ្ធភាពទាំងកម្រិតស្ថាប័ន និងបុគ្គល។

## ៣. ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

- **ចក្ខុវិស័យ**

  បង្កើតគោលនយោបាយអប់រំផ្អែកលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រនិងការវាយតម្លៃគោលនយោបាយអប់រំ ដើម្បីនាំមកនូវការអភិវឌ្ឍ និងនវានុវត្តន៍ក្នុងវិស័យអប់រំ។

- **បេសកកម្ម**

  នាយកដ្ឋានគោលនយោបាយ(ន.គ.ប) មានបេសកកម្ម:

- បង្កើតគោលនយោបាយអប់រំផ្អែកលើការស្រាវជ្រាវដោយប្រើវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ និងស្របតាមបរិបទកម្ពុជា
- តាមដានទិន្នាការជាតិ និងអន្តរជាតិ ដែលអាចមានឥទ្ធិពលលើការបង្កើតគោលនយោបាយអប់រំ

ផ្តល់ការគាំទ្របច្ចេកទេសដល់ការអនុវត្តការងាររបស់បុគ្គលិកអប់រំក្នុងការធ្វើការស្រាវជ្រាវដោយប្រើវិធីសាស្ត្រដែលប្រកបដោយនវានុវត្តន៍ និងស្របតាមបរិបទកម្ពុជា

- ជាវេទិការូបវន្តនិងទូរនិម្មិតសម្រាប់ការពិភាក្សាគោលនយោបាយអប់រំ ការចែករំលែក និងគ្រប់គ្រងចំណេះដឹង
- សម្របសម្រួលការអនុវត្តគោលនយោបាយអប់រំ យុវជន និងកីឡា តាមរយៈការពិនិត្យតាមដាន និងវាយតម្លៃនិងការផ្តល់ចំណេះដឹងលើអភិក្រមនៃការអនុវត្តគោលនយោបាយដល់ភាគីពាក់ព័ន្ធ។

- **គុណតម្លៃ**

នាយកដ្ឋានគោលនយោបាយ ប្រកាន់យកគុណតម្លៃស្នូលទាំង ៦គឺ (១)ស្មារតីក្រុម (២)ឧត្តមភាព (៣)ភាពជឿជាក់ (៤)ការច្នៃប្រឌិតនិងនវានុវត្តន៍ (៥) គណនេយ្យភាព និង(៦) ភាពជាម្ចាស់ ដើម្បីដឹកនាំសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃ កំណត់អំពីវប្បធម៌ស្ថាប័ន និងគាំទ្រចក្ខុវិស័យនិងបេសកកម្មរបស់នាយកដ្ឋាន។

## ៤. យុទ្ធសាស្ត្រ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ នាយកដ្ឋានគោលនយោបាយនឹងត្រូវដាក់ចេញផែនការយុទ្ធសាស្ត្រដូចខាងក្រោម៖

### លទ្ធផលទី ១៖ បង្កើតគោលនយោបាយអប់រំ ផ្អែកលើការស្រាវជ្រាវប្រកបដោយនវានុវត្តន៍ ស្របតាមបរិបទកម្ពុជា និងអភិក្រមនៃការចូលរួម

- **យុទ្ធសាស្ត្រទី ១៖ ស្រាវជ្រាវដើម្បីបង្កើតចំណេះដឹងតាមបែបវិទ្យាសាស្ត្រជាមូលដ្ឋានគ្រឹះដល់ការអភិវឌ្ឍគោលនយោបាយអប់រំ**

ការស្រាវជ្រាវក្នុងវិស័យអប់រំបង្កើតនូវចំណេះដឹងថ្មីៗ និងជាមធ្យោបាយដល់ការអភិវឌ្ឍគោលនយោបាយ និងការធ្វើឱ្យប្រសើរឡើងដល់អន្តរាគមន៍អប់រំ។ អ្នកបង្កើតគោលនយោបាយ និងអ្នករៀបចំផែនការត្រូវមានចំណេះដឹងថ្មីៗ។ យុទ្ធសាស្ត្រទី ១ ធានាឱ្យអត្ថបទ និងរបាយការណ៍ស្រាវជ្រាវបែបសិក្សា និងផ្អែកលើការពិសោធ ក៏ដូចជាប្រធានបទស្រាវជ្រាវទៅដល់អ្នកបង្កើតគោលនយោបាយ អ្នករៀបចំផែនការអប់រំ និងអ្នកតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

| យុទ្ធសាស្ត្រទី ១៖ ស្រាវជ្រាវដើម្បីបង្កើតចំណេះដឹងតាមបែបវិទ្យាសាស្ត្រជាមូលដ្ឋានគ្រឹះដល់ការអភិវឌ្ឍគោលនយោបាយអប់រំ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នកបង្កើតគោលនយោបាយ (ក្រសួងអយក.)<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន មន្ទីរ អយក. និង ការិយាល័យ អយក. នៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ) | ១. ចងក្រងប្រធានបទស្រាវជ្រាវ និងសំណួរស្រាវជ្រាវក្នុងវិស័យអប់រំ ដែលឆ្លើយតបទៅនឹងតម្រូវការដាក់លាក់នៃការអភិវឌ្ឍការអប់រំ ជាពិសេសប្រធានបទដែលពាក់ព័ន្ធនឹង៖<br>• វិធីសាស្ត្របង្រៀន<br>• កម្មវិធីសិក្សា<br>• ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការរៀន និងការបង្រៀន<br>• ការផ្តួចផ្តើម ការច្នៃប្រឌិត និងនវានុវត្តន៍ក្នុងការអប់រំ<br>• ការអប់រំ និងអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន<br>• ការអភិវឌ្ឍធនធានមនុស្ស<br>• ការគ្រប់គ្រង និងដឹកនាំសាលារៀន<br>• ការអភិវឌ្ឍយុវជន<br>• ភាពធន់ក្នុងវិស័យអប់រំ<br>• ការអប់រំតាមបែបឌីជីថល<br>២. ស្រាវជ្រាវលើប្រធានបទខាងលើ<br>៣. សរសេរ និងបោះពុម្ពអត្ថបទ និងរបាយការណ៍ស្រាវជ្រាវ | ▪ ប្រធានបទស្រាវជ្រាវ<br>▪ អត្ថបទស្រាវជ្រាវ<br>▪ របាយការណ៍ស្រាវជ្រាវ |

- **យុទ្ធសាស្ត្រទី ២៖ ធានាថាលទ្ធផលស្រាវជ្រាវត្រូវបានប្រើក្នុងការបង្កើតគោលនយោបាយអប់រំ និង រៀបចំផែនការ**

ដើម្បីធានាថាលទ្ធផលស្រាវជ្រាវត្រូវបានប្រើសម្រាប់ការបង្កើតគោលនយោបាយ និងរៀបចំផែនការ ន.គ.ប ផ្តល់អនុសាសន៍គោលនយោបាយអប់រំ ដែលអាចអនុវត្តបាន ដោយសង្ខេបរបាយការណ៍ស្រាវជ្រាវឱ្យងាយស្រួលយល់ ផ្សព្វផ្សាយ ឬផ្តល់ព័ត៌មានពីលទ្ធផលស្រាវជ្រាវក្រោមរូបភាពផ្សេងៗ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសក្នុងការអនុវត្តអនុសាសន៍ដែលផ្តល់ក្នុងរបាយការណ៍ស្រាវជ្រាវ។

| យុទ្ធសាស្ត្រទី ២៖ ប្រើលទ្ធផលស្រាវជ្រាវដើម្បីបង្កើតគោលនយោបាយអប់រំនិងរៀបចំផែនការ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នកបង្កើតគោលនយោបាយ(ក្រសួងអយក.)<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន មន្ទីរអយក. និងការិយាល័យអយកនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ) | ១. សរសេរឯកសារសង្ខេបគោលនយោបាយ<br>២. សរសេរសេចក្តីសង្ខេបរបាយការណ៍ស្រាវជ្រាវ<br>៣. បោះពុម្ពនិងផ្តល់របាយការណ៍ស្រាវជ្រាវដល់ភាគីពាក់ព័ន្ធ<br>៤. រៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវដល់អ្នកពាក់ព័ន្ធ<br>៥. រៀបចំវេទិកាស្រាវជ្រាវអប់រំ<br>៦. សរសេរនិងបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងកាលិកបត្រស្រាវជ្រាវ | ▪ ឯកសារសង្ខេបគោលនយោបាយ<br>▪ សេចក្តីសង្ខេបរបាយការណ៍ស្រាវជ្រាវ<br>▪ របាយការណ៍ស្រាវជ្រាវ<br>▪ អត្ថបទស្រាវជ្រាវ<br>▪ ចំនួនសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវ<br>▪ វេទិកាស្រាវជ្រាវអប់រំ |

- **យុទ្ធសាស្ត្រទី ៣៖ លើកកម្ពស់ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការបង្កើតគោលនយោបាយអប់រំ**

| យុទ្ធសាស្ត្រទី ៣៖ លើកកម្ពស់ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការបង្កើតគោលនយោបាយអប់រំ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នកបង្កើតគោលនយោបាយ(ក្រសួងអយក.)<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរអយក. និងការិយាល័យអយក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ) | ១. កំណត់ភាគីពាក់ព័ន្ធ និងវិភាគលើកត្តាផលប្រយោជន៍ សមត្ថភាព និងឥទ្ធិពលរបស់ពួកគេក្នុងដំណើររៀបចំគោលនយោបាយតាំងពីដំណាក់កាលនៃការកំណត់របៀបវារៈគោលនយោបាយ | ▪ សេចក្តីព្រាងគោលនយោបាយអប់រំ<br>▪ ព័ត៌មានត្រឡប់លើសេចក្តីព្រាងគោលនយបាយអប់រំ<br>▪ ចំនួនសិក្ខាសាលាពិគ្រោះយោបល់ |

| | | |
|---|---|---|
| ▪ នាយកសាលា<br>▪ គ្រូបង្រៀន<br>▪ ដៃគូអភិវឌ្ឍ<br>▪ សង្គមស៊ីវិល<br>▪ មាតាបិតាឬអាណាព្យាបាល<br>▪ អ្នកសិក្សា | ២. បង្កើតក្រុមការងាររៀបចំគោលនយោបាយដែលមានសមាសភាពតំណាងនៃភាគីពាក់ព័ន្ធចូលរួម<br>៣. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងវេទិកាពិភាក្សាគោលនយោបាយ ដើម្បីផ្ដល់ព័ត៌មានដល់ភាគីពាក់ព័ន្ធផ្សេងៗទៀត ដែលអាចនឹងមានផលប្រយោជន៍ឬផលប៉ះពាល់ដល់គោលនយោបាយ<br>៤. ប្រមូលព័ត៌មានត្រឡប់ លើសេចក្ដីព្រាងគោលនយោបាយតាមទម្រង់ ដោយផ្ទាល់ (សិក្ខាសាលាពិគ្រោះយោបល់ និងវេទិកាពិភាក្សាគោលនយោបាយអប់រំ) ដោយប្រយោល(អ៊ីម៉ែល វេបសាយ ប្លុក និងហ្វេសប៊ុក) ការស្ទង់មតិ ការប្រជុំពិភាក្សាជាក្រុម និងការសម្ភាសជាមួយអ្នករៀបចំគោលនយោបាយអប់រំ ក្នុងករណីចាំបាច់អប់រំ<br>៥. រៀបចំកិច្ចប្រជុំរាយការណ៍ពីដំណើរការរៀបចំគោលនយោបាយដល់អ្នករៀបចំគោលនយោបាយអប់រំ<br>៦. រៀបចំកិច្ចប្រជុំបច្ចេកទេសកម្រិតខ្ពស់ ដើម្បីពិភាក្សាអំពីជម្រើសគោលនយោបាយ និងសម្រេចលើទិសដៅទៅមុខ<br>៧. ផ្សព្វផ្សាយលទ្ធផលនៃដំណើរការតាក់តែងគោលនយោបាយ និងការវិវឌ្ឍនៃការបញ្ចប់ | ▪ ចំនួនវេទិកាពិភាក្សាគោលនយោបាយអប់រំ<br>▪ របាយការណ៍កិច្ចប្រជុំបច្ចេកទេសកម្រិតខ្ពស់ |

| | | |
|---|---|---|
| | ការតាក់តែងគោលនយោបាយអប់រំដល់សាធារណជន និងភាគីពាក់ព័ន្ធ។ | |

## លទ្ធផលទី ២៖ ច្នៃប្រឌិតការបង្រៀន ការរៀន វាយតម្លៃ និងអភិបាលកិច្ចសាលារៀន ដោយផ្អែកលើទ្រឹស្តី និងឧត្តមានុវត្តន៍

- **យុទ្ធសាស្ត្រទី ៤៖ ផ្តល់ការគាំទ្រ និងការណែនាំផ្នែកបច្ចេកទេសក្នុងការស្រាវជ្រាវ**

ការបង្រៀន និងការរៀនវាយតម្លៃអភិបាលកិច្ចសាលារៀនដែលមានប្រសិទ្ធភាព និងភាពច្នៃប្រឌិតតម្រូវឱ្យមានការស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ ដើម្បីឆ្លើយតបនឹងទស្សនៈនេះ នាយកដ្ឋានគោលនយោបាយ (ន.គ.ប) ប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ការប្រើប្រាស់ការស្រាវជ្រាវ និងលើកទឹកចិត្តដល់បុគ្គលិកអប់រំនៅថ្នាក់ក្រោមជាតិ គ្រូឧទ្ទេស នាយក សាលា និងគ្រូបង្រៀន ឱ្យធ្វើការស្រាវជ្រាវលើបញ្ហាអប់រំ។ យុទ្ធសាស្ត្រទី៤ នេះ ធានាផងដែរថា បុគ្គលិកអប់រំនៅថ្នាក់ក្រោមជាតិ គ្រូឧទ្ទេស នាយកសាលា និងគ្រូបង្រៀនបានទទួលនូវចំណេះដឹង និងជំនាញក្នុងការស្រាវជ្រាវ ព្រមទាំងការប្រើប្រាស់លទ្ធផលស្រាវជ្រាវក្នុងការធ្វើឱ្យប្រសើរដល់ការបំពេញការងាររបស់ខ្លួន។ ន.គ.ប នឹងបង្កើតសម្ភារៈឧបទេសសម្រាប់បណ្តុះបណ្តាលស្តីពីការស្រាវជ្រាវជាមូលដ្ឋាន ឧបករណ៍វិភាគគោលនយោបាយអប់រំ ព្រមទាំងឧបករណ៍វិភាគនិងដោះស្រាយបញ្ហាជាដើម។

| **យុទ្ធសាស្ត្រទី ៤៖ ផ្តល់ការគាំទ្រនិងការណែនាំផ្នែកបច្ចេកទេសក្នុងការស្រាវជ្រាវ** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នកធ្វើផែនការអប់រំ (នាយកដ្ឋាន និង មន្ទីរអេយក.)<br>▪ អ្នកអនុវត្ត (មន្ទីរអេយក. ការិយាល័យអេយក. មន្ត្រីអធិការកិច្ច | ១. បង្កើតសម្ភារៈបណ្តុះបណ្តាលផ្សេងៗ<br>២. រៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗ<br>៣. ផ្តល់ការប្រឹក្សាយោបល់ | អ្នកធ្វើផែនការ អ្នកអនុវត្តនិងគ្រូបង្រៀនបានទទួលការប្រឹក្សាយោបល់លើការស្រាវជ្រាវប្រតិបត្តិ |
| | ១. ធ្វើការសិក្សាពីតម្រូវការវគ្គបណ្តុះបណ្តាល<br>២. បង្កើតកម្មវិធីបណ្តុះបណ្តាល<br>៣. រៀបចំវគ្គបណ្តុះបណ្តាល<br>៤. បង្កើតសម្ភារៈបណ្តុះបណ្តាល | សម្ភារៈបណ្តុះបណ្តាលផ្សេងៗត្រូវបានបង្កើត និងប្រើប្រាស់ |

| | | |
|---|---|---|
| គ្រូឧទ្ទេស<br>នាយកសាលា<br>គ្រូបង្រៀន)<br>▪ អ្នកពាក់ព័ន្ធផ្នែកអប់រំផ្សេងៗទៀត | ១. ប្រឹក្សាយោបល់ដល់មន្ទីរអយក. និងការិយាល័យអយក. ក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិក្នុងការរៀបចំផែនការអប់រំ<br>២. ប្រឹក្សាយោបល់ដល់នាយកសាលាក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិក្នុងការគ្រប់គ្រង និងដឹកនាំសាលារៀន<br>៣. ប្រឹក្សាយោបល់ដល់គ្រូឧទ្ទេស គ្រូបង្រៀនក្នុងការធ្វើការស្រាវជ្រាវប្រតិបត្តិក្នុងការរៀន និងបង្រៀន<br>៤. គាំទ្រដល់គ្រូបង្រៀនក្នុងការចងក្រងនូវឧត្តមានុវត្តន៍ក្នុងការរៀន និងបង្រៀន<br>៥. បង្កើតឧបករណ៍កែលម្អការរៀន និងបង្រៀន<br>៦. រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើឧបករណ៍ | ឧបករណ៍កែលម្អការរៀន និងបង្រៀនត្រូវបានបង្កើត និងប្រើប្រាស់ |
| | ១. ធ្វើការពិនិត្យ និងបកប្រែឧបករណ៍វិភាគគោលនយោបាយអប់រំអន្តរជាតិ ឧបករណ៍វិភាគបញ្ហាអប់រំ<br>២.ធ្វើបរិបទនីយកម្មឧបករណ៍ទាំងនោះជាភាសាខ្មែរ<br>៣.រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើឧបករណ៍ទាំងនោះ<br>៤. បោះពុម្ពនិងផ្សព្វផ្សាយឧបករណ៍ទាំងនោះ | ឧបករណ៍វិភាគគោលនយោបាយផ្សេងៗជាភាសាខ្មែរត្រូវបានបង្កើតនិងប្រើប្រាស់ |

- **យុទ្ធសាស្ត្រទី ៥៖ បណ្តុះទម្លាប់ស្រាវជ្រាវជាមធ្យោបាយថ្មីសម្រាប់ការរៀន និងការអភិវឌ្ឍ**

ការលើកទឹកចិត្តជាគុណតម្លៃមួយក្នុងការធានាដល់ដំណើរការរៀនពេញមួយជីវិត។ អ្នកធ្វើផែនការ និងអ្នកអនុវត្តក្នុងវិស័យអប់រំ ត្រូវការជាចាំបាច់នូវផែនការអនុវត្តការងារដែលផ្អែកលើមូលដ្ឋានអំណះអំណាងច្បាស់លាស់មួយ ដើម្បីវិភាគអំពីការប្រតិបត្តិរបស់ពួកគេ។ ការស្រាវជ្រាវរបស់ ន.គ.ប ធ្វើឡើងក្នុងគោលបំណងស្នើឱ្យមានវិធីសាស្ត្រ យុទ្ធសាស្ត្រ និងមធ្យោបាយថ្មី ដែលអាចអនុវត្តបានប្រកបដោយភាពជោគជ័យ ទាំងអ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការ និងអ្នកអនុវត្តក្នុងវិស័យអប់រំ ដើម្បីធ្វើឱ្យស្ថានភាពអប់រំកាន់តែមានភាពប្រសើរឡើង។ គោលបំណងរបស់ ន.គ.ប តាមរយៈការធ្វើកិច្ចការស្រាវជ្រាវនិងបោះពុម្ពផ្សាយគឺដើម្បីជំរុញការកែលម្អគោលនយោបាយអប់រំ តាមរយៈការលើកកម្ពស់ការប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងអត្ថបទបោះពុម្ពផ្សាយ ដូចជា អត្ថបទក្នុងប្រព័ន្ធអនឡាញ កាលិកបត្រ ប័ណ្ណសន្និសីទ និងសៀវភៅដែលមានមូលដ្ឋានលើការស្រាវជ្រាវ។

| **យុទ្ធសាស្ត្រទី ៥: បណ្តុះទម្លាប់ស្រាវជ្រាវជាមធ្យោបាយថ្មីសម្រាប់ការរៀន និងការអភិវឌ្ឍ** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរ អយក.)<br>▪ អ្នកអនុវត្ត (ការិយាល័យ អយក. មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា គ្រូបង្រៀន)<br>▪ អ្នកស្រាវជ្រាវ បញ្ញវន្ត សិស្ស និស្សិត និង សាធារណជន | ១. អភិវឌ្ឍ Blogs Twitters និង Facebook<br>២. ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ តាមរយៈ Blogs Twitters Facebook និងព្រឹត្តិការណ៍ពិភាក្សាគោលនយោបាយអប់រំ<br>៣. សរសេរអត្ថបទ និងសៀវភៅសម្រាប់បោះពុម្ពផ្សាយ<br>៤. បង្ហាញលទ្ធផលនៃការស្រាវជ្រាវ ក្នុងវេទិកាស្រាវជ្រាវ | ការប្រើប្រាស់ការបោះពុម្ពផ្សាយរបស់ក.ស.អ<br>• Blogs<br>• អត្ថបទ<br>• ទម្រង់ការ<br>• ឯកសារការងារ<br>• របាយការណ៍ស្រាវជ្រាវ |

**លទ្ធផលទី ៣៖ លើកកម្ពស់ការចែករំលែកចំណេះដឹងនិងការបង្កើតសហគមន៍រៀនសូត្រ**

- **យុទ្ធសាស្ត្រទី ៦៖ ផ្តល់ធនធានអប់រំក្រោមរូបភាពផ្សេងៗដល់អ្នករៀបចំគោលនយោបាយ បុគ្គលិកអប់រំ អ្នកសិក្សា សាធារណជន និងអ្នកពាក់ព័ន្ធអប់រំផ្សេងៗទៀត**

ចំណេះដឹងជាទ្រព្យដ៏មានតម្លៃរបស់ ន.គ.ប ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែ ចំណេះដឹងជារឿយៗមិនត្រូវបានចងក្រងទុក ពិបាករក និងមិនមានវេទិកាសម្រាប់ចែករំលែក។ ការគ្រប់គ្រងចំណេះដឹងនៅក្នុង ន.គ.ប បានល្អ នឹងបង្កើនសមត្ថភាពផ្ទៃក្នុង ប្រសិទ្ធភាព និងគុណផលការងារ និងលើកកម្ពស់ការរៀនពេញមួយជីវិតរបស់សាធារណជន។ យុទ្ធសាស្ត្រទី ៦ ផ្តោតលើការគ្រប់គ្រងចំណេះដឹងតាមយន្តការនានាដើម្បីផ្តល់ព័ត៌មាន លើកទឹកចិត្ត និងជួយគាំទ្រដល់អ្នករៀបចំគោលនយោបាយ បុគ្គលិកអប់រំ អ្នកសិក្សា សាធារណជន និងអ្នកពាក់ព័ន្ធអប់រំផ្សេងៗទៀតក្នុងការអភិវឌ្ឍចំណេះវិជ្ជា ការច្នៃប្រឌិត និងនវានុវត្តន៍នៅក្នុងការប្រតិបត្តិការងាររបស់ខ្លួន។

| **យុទ្ធសាស្ត្រទី ៦: ផ្តល់ធនធានអប់រំក្រោមរូបភាពផ្សេងៗដល់អ្នករៀបចំគោលនយោបាយ បុគ្គលិក អប់រំ សិស្ស និស្សិត សាធារណជន និងអ្នកពាក់ព័ន្ធអប់រំផ្សេងៗទៀត** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំគោលនយោបាយអប់រំ<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាននិងមន្ទីរអេយក.)<br>▪ អ្នកអនុវត្ត (ការិយាល័យអយក. មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា គ្រូបង្រៀន)<br>▪ អ្នកស្រាវជ្រាវ សិស្ស និស្សិត បញ្ញវន្ត និងសាធារណជន | ១. ប្រមូលសៀវភៅ ឯកសារ របាយការណ៍ស្រាវជ្រាវថ្មីៗ ឯកសារគោលនយោបាយអប់រំ និងផែនការដាក់ក្នុងបន្ទប់ធនធាន<br>២. រៀបចំប្រព័ន្ធគ្រប់គ្រងបន្ទប់ធនធាន ( Library management system )<br>៣. កសាងបន្ទប់ធនធានទូរនិម្មិត ( Upgrade Physical Resource Center to virtual library )<br>៤. បង្កើតមជ្ឈមណ្ឌលគ្រប់គ្រងគោលនយោបាយតាមអនឡាញ ( Policy Management Hub, International and national policies )<br>៥. បង្កើត និងអភិវឌ្ឍវេបសាយ ន.គ.ប<br>៦. សហការជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីទទួលបានសៀវភៅដែលទទួល | ▪ សៀវភៅ ឯកសារ របាយការណ៍ស្រាវជ្រាវថ្មីៗ<br>▪ ឯកសារគោលនយោបាយ និងផែនការ<br>▪ បន្ទប់ធនធានទូរនិម្មិត<br>▪ មជ្ឈមណ្ឌលគ្រប់គ្រងគោលនយោបាយអប់រំ<br>▪ វេបសាយ ន.គ.ប |

| | | |
|---|---|---|
| | ស្គាល់ជាលក្ខណៈអន្តរជាតិ ក្រោមគម្រោងមូលនិធិអាស៊ី(RUPP-TAF Books for Asia)<br>៦. ចូលជាសមាជិកនៃបណ្ណាល័យជាតិ អន្តរជាតិ និងកាលិកបត្រជាតិនិងអន្តរជាតិ<br>៧. ចូលជាសមាជិកនៃសហគមន៍វិជ្ជាជីវៈនានា (subscribe the membership of Communities of Practice) | |

- **យុទ្ធសាស្ត្រទី ៧៖ ផ្តល់វេទិការូបវន្តនិងទូរនិម្មិតសម្រាប់ការពិភាក្សាគោលនយោបាយអប់រំ និងការចែករំលែកចំណេះដឹង**

យុទ្ធសាស្ត្រទី ៧ ជានាឱ្យចំណេះដឹងត្រូវបានចែករំលែកដល់អ្នករៀបចំគោលនយោបាយអប់រំ បុគ្គលិកអប់រំ អ្នកសិក្សា សាធារណជន និងអ្នកពាក់ព័ន្ធអប់រំផ្សេងៗទៀត តាមរយៈវេទិកា កិច្ចប្រជុំ កិច្ចពិភាក្សា សិក្ខាសាលា សន្និសីទ និងព្រឹត្តិការណ៍នានា។

| **យុទ្ធសាស្ត្រទី ៧: ផ្តល់វេទិការូបវន្តនិងទូរនិម្មិតសម្រាប់ការពិភាក្សាគោលនយោបាយនិងការចែករំលែកចំណេះដឹង** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំគោលនយោបាយអប់រំ<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរ អយក.)<br>▪ អ្នកអនុវត្ត (ការិយាល័យ អយក មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា គ្រូបង្រៀន)<br>▪ អ្នកស្រាវជ្រាវ សិស្ស និស្សិត បញ្ញវន្ត និងសាធារណជន | ១. រៀបចំកិច្ចពិភាក្សាគោលនយោបាយអប់រំ<br>២. រៀបចំសិក្ខាសាលា សន្និសីទ និងកិច្ចប្រជុំចែករំលែកចំណេះដឹង<br>៣. បង្កើតវេទិកាទូរនិម្មិតចែករំលែកចំណេះដឹង ដូចជា៖<br>• វេបសាយ<br>• វេទិកាពិភាក្សាអនឡាញ<br>• Zoom<br>• Facebook<br>• Blogs etc… | • ចំនួនកិច្ចប្រជុំពិភាក្សាគោលនយោបាយអប់រំ<br>• ចំនួនសិក្ខាសាលាសន្និសីទ កិច្ចប្រជុំ |

## លទ្ធផលទី ៤៖ កាត់បន្ថយបញ្ហាគម្លាត នៃគោលនយោបាយអប់រំ និងការអនុវត្ត គោលនយោបាយ

- **យុទ្ធសាស្ត្រទី ៨៖ រៀបចំយុទ្ធសាស្ត្រគាំទ្រការអនុវត្តគោលនយោបាយអប់រំ**

យុទ្ធសាស្ត្រទី ៨ ធានាឱ្យគោលនយោបាយអប់រំត្រូវបាន ដឹង យល់ និងអនុវត្តបានដោយបុគ្គលិកអប់រំ។ យុទ្ធសាស្ត្រនេះត្រូវគិតពិចារណាតាំងពីដំណើរការការអភិវឌ្ឍគោលនយោបាយអប់រំ។

| យុទ្ធសាស្ត្រទី ៨: រៀបចំយុទ្ធសាស្ត្រគាំទ្រការអនុវត្តគោលនយោបាយអប់រំ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| អ្នករៀបចំគោលនយោបាយអប់រំ<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរអយក)<br>▪ អ្នកអនុវត្ត (ការិយាល័យអយក មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា គ្រូបង្រៀន) | ១. រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ជាទៀងទាត់ ស្តីពីគោលនយោបាយអប់រំ និន្នាការអប់រំជាតិ តំបន់ និងអន្តរជាតិថ្មីៗដល់នាយកដ្ឋានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>២. រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការវិវឌ្ឍនៃគោលនយោបាយអប់រំ ដើម្បីធ្វើបច្ចុប្បន្នភាពដល់គ្រប់នាយកដ្ឋានទាំងអស់។<br>៣. ផ្សព្វផ្សាយគោលនយោបាយអប់រំ និន្នាការអប់រំថ្មីៗនិងឯកសារប្រវត្តិនៃគោលនយោបាយអប់រំនៅលើគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡានិងមជ្ឈមណ្ឌលគ្រប់គ្រងគោលនយោបាយអប់រំរបស់ន.គ.ប។<br>៤. ផ្តល់ការគាំទ្រនិងយោបល់ផ្នែកបច្ចេកទេសលើការអនុវត្តគោលនយោបាយដល់នាយកដ្ឋានជំនាញ និងថ្នាក់ក្រោមជាតិ<br>៥. បណ្តុះបណ្តាលនាយកដ្ឋានជំនាញថ្នាក់ក្រោម ជាតិ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ស្តីពីការ អនុវត្តគោលនយោបាយអប់រំ។ | ▪ សិក្ខាសាលាផ្សព្វផ្សាយ<br>▪ កិច្ចប្រជុំផ្តល់យោបល់បច្ចេកទេស<br>▪ វគ្គបណ្តុះបណ្តាល<br>▪ ពីគោលនយោបាយដែលបានបង្ហោះក្នុងវេបសាយ គេហទំព័រក្រសួងអយក. និង<br>▪ មជ្ឈមណ្ឌលគ្រប់គ្រងគោលនយោបាយអប់រំរបស់ ន.គ.ប |

- យុទ្ធសាស្ត្រទី ៩៖ ពិនិត្យឡើងវិញនូវគោលនយោបាយអប់រំ

| យុទ្ធសាស្ត្រទី ៩: ពិនិត្យឡើងវិញនូវគោលនយោបាយអប់រំ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំគោលនយោបាយអប់រំ<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរអេយក)<br>▪ អ្នកអនុវត្ត (ការិយាល័យអេយក មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា គ្រូបង្រៀន) | ១. កំណត់គោលនយោបាយដែលត្រូវពិនិត្យឡើងវិញ (វិភាគតម្រូវការនៃការពិនិត្យឡើង វិញគោលនយោបាយអប់រំ)<br>២. ពិនិត្យឡើងវិញនូវគោលនយោបាយដោយមានការចូលរួមរបស់ភាគីពាក់ព័ន្ធនិងអ្នកជំនាញគោលនយោបាយនិងធ្វើការស្រាវជ្រាវពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយដែលនឹងត្រូវពិនិត្យឡើងវិញ<br>៣. សរសេររបាយការណ៍ស្តីពីការពិនិត្យឡើងវិញ គោលនយោបាយអប់រំ<br>៤. ធ្វើបទបង្ហាញស្តីពីរបាយករណ៍ស្តីពីការពិនិត្យឡើងវិញគោលនយោបាយអប់រំ | ▪ ចំនួនគោលនយោបាយអប់រំដែលត្រូវពិនិត្យឡើងវិញ<br>▪ របាយការណ៍ស្តីពីការពិនិត្យឡើងវិញគោលនយោបាយអប់រំ |

- យុទ្ធសាស្ត្រទី ១០៖ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ

| យុទ្ធសាស្ត្រទី ១០: ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំគោលនយោបាយអប់រំ<br>▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន និងមន្ទីរអេយក) | ១. បង្កើតឧបករណ៍ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ<br>២. ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ | ▪ ឧបករណ៍ពិនិត្យតាមដាននិងវាយតម្លៃគោលនយោបាយអប់រំ |

| | | |
|---|---|---|
| ▪ អ្នកអនុវត្ត(ការិយាល័យ អយក មន្ត្រីអធិការកិច្ច សាលារៀន នាយកសាលា និងគ្រូបង្រៀន) | • ស្ទង់មតិកម្រងសំណួរ<br>• ការសម្ភាស<br>• ការពិភាក្សាក្រុម<br>៣. សរសេររបាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃ<br>៤. ធ្វើបទបង្ហាញស្តីពី របាយការណ៍ពិនិត្យតាមដាន និងវាយតម្លៃ<br>៥. សរសេរសេចក្តីសង្ខេប ឬឯកសារសង្ខេបគោលនយោបាយអប់រំ | ▪ របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃ សរសេរសេចក្តីសង្ខេប ឬឯកសារសង្ខេបគោលយោបាយអប់រំ |

## លទ្ធផលទី ៥៖ ពង្រឹងសមត្ថភាពស្ថាប័ននិងបុគ្គលឱ្យស្របតាមបរិបទសតវត្សរ៍ទី ២១ សម័យឌីជីថល និងដើម្បីឆ្លើយតបនៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព

- **យុទ្ធសាស្ត្រទី ១១៖ លើកកម្ពស់សមត្ថភាពស្ថាប័ន**

សមត្ថភាពស្ថាប័ន លើកកម្ពស់អភិបាលកិច្ចល្អនៅក្នុង ន.គ.ប ដែលធ្វើឱ្យប្រសើរដល់ដំណើរការនៃការអភិវឌ្ឍគោលនយោបាយ និងការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអប់រំ។ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ពង្រឹង និងធានានូវការរីកចម្រើនរបស់ស្ថាប័នប្រកបដោយចីរភាព ដើម្បីសម្រេចបេសកកម្មរបស់ ន.គ.ប។

| **យុទ្ធសាស្ត្រទី ១១: លើកកម្ពស់សមត្ថភាពស្ថាប័ន** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| អគ្គនាយកគោលនយោបាយ និងផែនការ<br>▪ អគ្គនាយករងទទួលបន្ទុក<br>▪ ប្រធាន ន.គ.ប<br>▪ អនុប្រធាន ន.គ.ប | **ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព**<br>១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ផែនការសកម្មភាព (ប្រចាំឆ្នាំ ខ្លី មធ្យម និងវែង) ផែនការថវិកា ដែលមានភាពស៊ីសង្វាក់ និងសង្គតិភាពដោយមានការចូលរួមរបស់ថ្នាក់ | ▪ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានតម្លាភាព<br>▪ ប្រព័ន្ធគុណផលការងារ |

| | | |
|---|---|---|
| ▪ ប្រធានការិយាល័យ<br>▪ អនុប្រធានការិយាល័យ<br>▪ មន្ត្រី | ដឹកនាំ និងមន្ត្រី ន.គ.ប ទាំងអស់<br>២. ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងថវិកាដល់មន្ត្រី ន.គ.ប ទាំងអស់<br>៣. ឆ្លុះបញ្ចាំងលើការអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាដោយកមានការចូលរួមរបស់ថ្នាក់ដឹកនាំនិងមន្ត្រី ន.គ.ប<br>៤. ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តផែនការសកម្មភាព និងផែនការថវិកា<br>**រចនាសម្ព័ន្ធ និងការសម្រេចចិត្ត**<br>៥. រៀបចំរចនាសម្ព័ន្ធ ការបែងចែកកម្រិតនៃការងារ<br>៦. កំណត់តួនាទីភារកិច្ចរបស់ការិយាល័យច្បាស់លាស់<br>**ការគ្រប់គ្រងគុណផលការងារនិងការផ្តល់ការលើកទឹកចិត្ត**<br>៧. កំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីឱ្យបានច្បាស់លាស់<br>៨. រៀបចំប្រព័ន្ធគ្រប់គ្រងគុណផលការងារនិងការផ្តល់ការលើកទឹកចិត្តសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី ន.គ.ប<br>៩. អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលការងារសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី ន.គ.ប | ▪ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តការងារ<br>▪ រចនាសម្ព័ន្ធនិងការបែងចែកការទទួលខុសត្រូវច្បាស់ លាស់ |

| | | |
|---|---|---|
| | **ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងការទំនាក់ទំនង**<br>១០.បង្កើតប្រព័ន្ធ គ្រប់គ្រងទិន្នន័យ រដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិក (Dropbox, google drive, Website, Intranet, server ជាដើម) និងចាត់តាំងអ្នកគ្រប់គ្រងទិន្នន័យព័ត៌មានច្បាស់លាស់<br>១១.បង្កើតយន្តការទំនាក់ទំនងក្នុង និងក្រៅនាយកដ្ឋាន<br>**ប្រព័ន្ធហិរញ្ញវត្ថុ និងលទ្ធកម្ម**<br>១២.បង្កើតយន្តការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាព ក្នុងការងារហរិញ្ញវត្ថុ<br>**អភិបាលកិច្ចឌីជីថល**<br>១៣. បង្កើត និងអភិវឌ្ឍវេបសាយ ន.គ.ប<br>១៤. បង្កើត INTRANET នៅក្នុង ន.គ.ប<br>**គោលនយោបាយ ន.គ.ប**<br>១៥. អនុវត្តគោលការណ៍បរិយាបន្ន និងសមធម៌(ឧទាហរណ៍ៈ សមភាពយេនឌ័រថ្នាក់ដឹកនាំនិងមន្ត្រីជាស្ត្រីនិងជាជនពិការជាដើម) មាននៅក្នុង ន.គ.ប<br>១៦. រៀបចំគោលការណ៍ណែនាំស្តីពីធនធានមនុស្ស ហិរញ្ញវត្ថុ រដ្ឋបាល និងទំនាស់ផលប្រយោជន៍ ដែលឆ្លើយតបនឹងតម្រូវការមន្ត្រី និងច្បាប់ជាធរមានដោយមានការចូលរួមពីមន្ត្រី ន.គ.ប | |

| | | |
|---|---|---|
| | ១៧. អនុវត្តគោលការណ៍តម្លាភាពនិងភាពគ្មានបក្ខពួកក្នុង ន.គ.ប។ | |

- **យុទ្ធសាស្ត្រទី ១២៖ លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពបុគ្គល**

សមត្ថភាពរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់គឺជាកត្តាគន្លឹះធ្វើឱ្យប្រសើរដល់ដំណើរការនៃការអភិវឌ្ឍគោលនយោបាយ និងការពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តគោលនយោបាយអប់រំ។ ការអភិវឌ្ឍសមត្ថភាពបុគ្គលនឹងធ្វើឱ្យប្រសើរដល់សមត្ថភាពមន្ត្រីគ្រប់លំដាប់ថ្នាក់ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃការអប់រំដែលរួមមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល និងផ្តល់ឱកាសដល់មន្ត្រីនាយកដ្ឋានគោលនយោបាយបានចូលរួមក្នុងសកម្មភាពនៃការសិក្សាពេញមួយជីវិត។ ផែនការសកម្មភាពអភិវឌ្ឍសមត្ថភាពបុគ្គលសម្រាប់រយៈពេល៥ឆ្នាំ នឹងត្រូវរៀបចំដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ។

| **យុទ្ធសាស្ត្រទី ១២: លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពបុគ្គល** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ ប្រធាន ន.គ.ប<br>▪ អនុប្រធាន ន.គ.ប<br>▪ ប្រធានការិយាល័យ<br>▪ អនុប្រធានការិយាល័យ<br>▪ មន្ត្រី | ១. ផ្តល់ការបណ្តុះបណ្តាលរយៈពេលវែង នៅក្នុងនិងក្រៅប្រទេស ជាពិសេសការបណ្តុះបណ្តាលវគ្គសញ្ញាបត្រ(Degree program)<br>២. ផ្តល់ការបណ្តុះបណ្តាលជំនាញដែលចាំបាច់ (Specialized Courses) ក្នុងប្រទេស និងក្រៅប្រទេស ដែលជាផ្នែកមួយនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីបង្កើនសមត្ថភាពសំខាន់ៗ ចំនួន ៥ ៖<br>• **សមត្ថភាពស្រាវជ្រាវ**<br>• **សមត្ថភាពអភិវឌ្ឍគោលនយោបាយ**<br>• **សមត្ថភាពបច្ចេកវិទ្យាព័ត៌មាន** | ▪ ចំនួនវគ្គបណ្តុះបណ្តាល<br>▪ ចំនួនកិច្ចប្រជុំចែករំលែកចំណេះដឹង<br>▪ ចំនួនអត្ថបទបោះពុម្ពរួមគ្នា<br>▪ ចំនួនវគ្គហ្វឹកហាត់ |

| | | |
|---|---|---|
| | • **សមត្ថភាពរៀបចំផែនការសកម្មភាព ផែនការថវិកានិងការសរសេរគម្រោង**<br>• **សមត្ថភាពអន្តរទំនាក់ទំនង**<br>៣. រៀបចំកិច្ចប្រជុំចែករំលែកចំណេះដឹង រៀងរាល់ថ្ងៃសុក្រ ក្នុងរៀងរាល់ពីរសប្តាហ៍ម្តង<br>៤. បង្កើតក្រុមរៀនសូត្រជាមួយគ្នា (Action Learning Group) ឬសហគមន៍សិក្សាក្នុងនាយកដ្ឋាន និងជាមួយនាយកដ្ឋាននៅក្នុងចង្កោមអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ<br>៥. សរសេរ និងបោះពុម្ពអត្ថបទរួមគ្នា<br>៦. ផ្តល់ការហ្វឹកហាត់ និងការបង្ហាត់បង្ហាញដល់ថ្នាក់ដឹកនាំនិងមន្ត្រី ន.គ.ប ពីអ្នកជំនាញជាតិ និងអន្តរជាតិ (Mentoring and coaching) លើជំនាញសមត្ថភាពទាំង ៥។ | |

- **យុទ្ធសាស្ត្រទី ១៣ ៖ លើកកម្ពស់សុខមាលភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រី ន.គ.ប**

| **យុទ្ធសាស្ត្រទី ១៣: លើកកម្ពស់សុខមាលភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រី ន.គ.ប** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ<br>▪ អគ្គនាយករងទទួលបន្ទុក<br>▪ ប្រធាន ន.គ.ប<br>▪ អនុប្រធាន ន.គ.ប | ១. បង្កើតបរិស្ថាន និងបរិយាកាសការងារមេត្រីភាព (កន្លែងការងារអនាម័យដាំរុក្ខជាតិបៃតង ផ្ទាំងសិល្បៈ ពាក្យស្លោក បន្ទប់ទឹកជាដើម)<br>២. បង្កើតបរិស្ថានធម្មជាតិ និងបរិស្ថាន កីឡា | ▪ កន្លែងការងារមេត្រី<br>▪ មន្ត្រីមានសុខមាលភាព |

| | | |
|---|---|---|
| ▪ ប្រធានការិយាល័យ<br>▪ អនុការិយាល័យ<br>▪ មន្ត្រី | ៣. ផ្តល់ប្រឹក្សាយោបល់(Counseling)ដល់មន្ត្រី ន.គ.ប<br>៤. បណ្តុះបណ្តាលការគ្រប់គ្រង និងអប់រំចិត្ត ព្រមទាំងការអនុវត្តការធ្វើសមាធិនៅក្នុងកន្លែងការងារ<br>៥. រៀបចំកម្មវិធីជួបជុំនិងដំណើរកំសាន្តនានា។ | |

- **យុទ្ធសាស្ត្រទី ១៤៖ ជំរុញកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ និងអន្តរជាតិដើម្បីបង្កើត និងផ្លាស់ប្តូរចំណេះដឹង**

ក្នុងនាមជាធនាគារខួរក្បាលរបស់ក្រសួងអប់រំ យុវជន និងកីឡា ន.គ.ប បានបង្កើតទំនាក់ទំនងជាមួយស្ថាប័នស្រាវជ្រាវជាតិ តំបន់ និងអន្តរជាតិ ដូចជា KEDI PISA-D និង SEAMEO INNOTEC។ ការអភិវឌ្ឍវិជ្ជាជីវៈគឺជាដំណើរការជាប្រចាំដែលតម្រូវឱ្យស្ថាប័ន ន.គ.ប និងសមាជិករបស់ខ្លួនបង្កើនសមត្ថភាពស្រាវជ្រាវ និងការរៀបចំគោលនយោបាយ តាមរយៈភាពជាដៃគូថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ដោយសារការស្រាវជ្រាវក្នុងវិស័យអប់រំកាន់តែបានប្រើប្រាស់ជាសកល ន.គ.ប ចាំបាច់ត្រូវចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវជាតិ តំបន់ និងអន្តរជាតិ។ ដូច្នេះ ន.គ.ប នឹងបង្កើតអនុស្សរណៈនៃការយោគយល់ និងគម្រោងស្រាវជ្រាវ ធ្វើការស្រាវជ្រាវ និងការបោះពុម្ពផ្សាយរួមគ្នា។

| **យុទ្ធសាស្ត្រទី ១៤ ៖ ជំរុញកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីបង្កើត និងផ្លាស់ប្តូរចំណេះដឹង** | | |
|---|---|---|
| **ភាគីពាក់ព័ន្ធ** | **សកម្មភាព** | **លទ្ធផល** |
| ▪ អ្នករៀបចំផែនការអប់រំ (នាយកដ្ឋាន មន្ទីរអយក.)<br>▪ អ្នកអនុវត្ត (ការិយាល័យអយក. មន្ត្រីអធិការកិច្ចសាលារៀន នាយកសាលា និងគ្រូបង្រៀន)<br>▪ អ្នកស្រាវជ្រាវ បញ្ញវន្ត និង | ១. កំណត់ដៃគូសំខាន់ៗ<br>២. បង្កើតទំនាក់ទំនងជាផ្លូវការជាមួយស្ថាប័នសិក្សាជាតិ តំបន់ និងអន្តរជាតិ<br>៣. ចុះកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូ<br>៤. រៀបចំកិច្ចសន្ទនាគោលនយោបាយអប់រំ<br>៥. រៀបចំសំណើស្រាវជ្រាវរួមគ្នា<br>៦. សិក្សាស្រាវជ្រាវរួមគ្នា | ▪ អនុស្សរណៈនៃការយោគយល់ជាមួយអង្គការជាតិ តំបន់ និងអន្តរជាតិ<br>▪ គម្រោងស្រាវជ្រាវរួមគ្នា |

| | | |
|---|---|---|
| បណ្តាញជាតិ និងអន្តរជាតិ | ៧. កៀរគរធនធាន<br>៨. សំយោគ និងចងក្រងអត្ថបទស្រាវជ្រាវ<br>៩. រៀបចំវេទិកាអប់រំកម្រិតជាតិ តំបន់ និងអន្តរជាតិរួមគ្នា | ព្រឹត្តិការណ៍អន្តរជាតិត្រូវបានចូលរួម |

## ៥. ធនធានហិរញ្ញវត្ថុ

ហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការរបស់ ន.គ.ប សម្រាប់រយៈពេលវែងនៃផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ២០២១-២០២៥ បានមកពីរាជរដ្ឋាភិបាលកម្ពុជា ក្រោមក្របខណ្ឌថវិកាកម្មវិធីដោយបានផ្តល់ថវិកាចំនួន ១,១០០ លានរៀលរៀងរាល់ឆ្នាំ។ គម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ក្រោមកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB-USESDP) ដែលនឹងបន្តផ្តល់ថវិកាជារៀងរាល់ឆ្នាំចំនួន ៩0,000 ដុល្លារអាមេរិក រហូតដល់ឆ្នាំ ២០២១។ មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព (CDPF) ប្តេជ្ញាផ្តល់ថវិកា ៨0,000 ដុល្លារអាមេរិកក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០២៣។ WFP ផ្តល់ថវិកាចំនួន ២៥,000 ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ន.គ.ប ព្យាយាមកៀរគរធនធានពីប្រភពផ្សេងៗទៀតតាមរយៈយុទ្ធសាស្ត្រភាពជាដៃគូ។

## ៦. តាមដាន និងវាយតម្លៃ

ន.គ.ប ប្តេជ្ញាធ្វើឱ្យប្រសើរឡើងដល់ការរៀន និងការចែករំលែកចំណេះដឹងក្នុងស្ថាប័ន ក៏ដូចជាការអភិវឌ្ឍវិធីសាស្ត្រដើម្បីបំពេញតាមគោលដៅរបស់ស្ថាប័ន និងគោលដៅអភិវឌ្ឍវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ន.គ.ប តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់លើប្រតិបត្តិការ កម្មវិធី និងគម្រោងស្រាវជ្រាវ ដើម្បីធានាថាសកម្មភាពរបស់យើងឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកដែលចង់បាន។